ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៥ សហវ.[illegible]

## សារាចរណែនាំ

## ស្តីពីការបិទបញ្ជីចំណូល ចំណាយ

## និង ធ្វើរបាយការណ៍បូកសរុបទូទាត់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៧

យោងមាត្រា ១២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងប្រការ ៣២ ប្រការ ៣៣ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសក្នុងការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍សំរេចទូទាត់ថវិកាខេត្ត ក្រុងឆ្នាំ ២០០៧ ដូចខាងក្រោម ៖

**១.** អភិបាលខេត្ត ក្រុងដែលជាអាណាប័កដើមខ្សែ ត្រូវខិតខំជំរុញចំណូលសារពើពន្ធ និងប្រមូលចំណូលមិនមែនសារពើពន្ធ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន បង់ចូលថវិកាខេត្ត ក្រុងទាំងអស់យ៉ាងយូរ ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ។ ប្រសិនបើមានកាយឺតយ៉ាវក្រោយថ្ងៃកំណត់នេះ រតនាគារខេត្ត ក្រុង ត្រូវកត់ត្រាចូលជាចំណូលថវិកាខេត្ត ក្រុងឆ្នាំ ២០០៨ ។

**២.** ការស្នើសុំថវិកាឧបត្ថម្ភតុល្យភាព ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ ត្រូវបញ្ជូនសំណើលិខិតស្នើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ។

**៣.** ការធ្វើនិយ័តភាពឥណទានដែលពាក់ព័ន្ធដល់ការសុំអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ទាំងអស់ត្រូវបញ្ជូនសំណើលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ។

**៤.** ចំពោះឥណទានដែលបានធ្វើនិយ័តកម្ម និងបានការអនុញ្ញាតដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុងត្រូវខិតខំរៀបចំគំរោងអោយបានសមស្រប ក្នុងការអនុវត្តនីតិវិធីលទ្ធកម្ម ដើម្បីអោយការអនុវត្តគំរោងអាចសំរេចបានទាន់ពេលវេលា ។

៥. រតនាគារខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់នៅម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ។ ដូច្នេះក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ត្រូវរួសរាន់ប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការ ដើម្បីធ្វើអាណត្តិ (ទាំងអាណត្តិទូទាត់ត្រង់ ទាំងអាណត្តិទូទាត់រដ្ឋទេយ្យបុរេប្រទាន) បញ្ជូនទៅផ្នែកទិដ្ឋាការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួចដាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុង ចុះហត្ថលេខា និងបញ្ជូនទៅរតនាគារខេត្ត ក្រុងអោយបានមុនម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ។

៦. នៅចុងថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ រតនាគារខេត្ត ក្រុង ត្រូវដំណើរការផ្ទេរសមតុល្យគណនីចំណូល ចំណាយរបស់សាលាខេត្ត ក្រុង ចូលទៅក្នុងគណនីលទ្ធផលនៃការិយបរិច្ឆេទ ។ ប្រសិនបើមានអតិរេករតនាគារខេត្ត ក្រុងត្រូវជូនដំណឹងទៅសាលាខេត្ត ក្រុងអោយធ្វើសលាកប័ត្រចំណូលបង់ចូលថវិការដ្ឋឆ្នាំ ២០០៧ ជាបន្ទាន់ក្នុងករណីមានការយឺតយ៉ាវស្ថិតនៅចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ នោះកាលបរិច្ឆេទនៃការបង់ត្រូវចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ដែរ ។ ផ្ទុយទៅវិញប្រសិនបើហួសកាលកំណត់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ហើយសាលាខេត្ត ក្រុងនៅតែពុំទាន់បានបង់ទេនោះ គឺរតនាគារខេត្ត ក្រុងត្រូវម្ចាស់ការផ្ទេរដោយស្វ័យប្រវត្តិចូលជាចំណូលថវិការដ្ឋ ហើយត្រូវជូនដំណឹងទៅសាលាខេត្ត ក្រុងអោយបានជ្រាប ។ កាលបរិច្ឆេទនៃការផ្ទេរនេះ ក៏ត្រូវចាត់ទុកថាជាកិច្ចប្រតិបត្តិការថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែរ ។

៧. កិច្ចប្រតិបត្តិការនិយ័តភាវូបនីយកម្មរបស់រតនាគារ សំរាប់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៧ ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ ។ កិច្ចប្រតិបត្តិការនេះ ត្រូវបានពិនិត្យកត់ត្រាជាលេខនាបន្ថែម នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលទាក់ទងទៅនឹង :

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬនៃចំណាយ ដែលបានពិនិត្យកត់ត្រាជាលេខនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។
- អាណត្តិនិយ័តភាវូបនីយកម្ម ដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរដ្ឋទេយ្យបុរេប្រទានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ។
- ការកែប្រែលេខនាខុស ។

៨. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៨ រាល់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាខេត្ត ក្រុងឆ្នាំថ្មី ត្រូវកត់ត្រាចូលក្នុងគណនីថវិកាខេត្ត ក្រុងឆ្នាំ ២០០៨ ។

៩. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៨ រតនាគារខេត្ត ក្រុង និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងត្រូវដំណើរការបូកសរុបនិងផ្ទៀងផ្ទាត់អំពីការអនុវត្តន៍ចំណូល ចំណាយថវិកាខេត្ត ក្រុងឆ្នាំ២០០៧ ដោយរតនាគារខេត្ត ក្រុងត្រូវបង្កើតតារាងតុល្យភាពគណនីប្រចាំឆ្នាំ និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងត្រូវធ្វើតារាងបូកសរុប

ចំណូល ចំណាយថវិកាខេត្ត ក្រុងតាមមាតិកាថវិកា រួចធ្វើកំណត់ បង្ហាញជាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុង ពិនិត្យសំរេចនិងចុះហត្ថលេខា ។ អភិបាលខេត្ត ក្រុង ត្រូវធ្វើលិខិតបញ្ជូនតារាងតុល្យភាពគណនីប្រចាំឆ្នាំ តារាងបូកសរុបចំណូល ចំណាយ និងកំណត់បង្ហាញខាងលើ ទៅក្រសួងមហាផ្ទៃ ចំនួន ០១ច្បាប់ និង មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ច្បាប់ អោយបានមុនថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨ ដើម្បីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុប និងរៀបចំទូវរបាយការណ៍សំរេចទូទាត់ថវិកាខេត្ត ក្រុងរួមមួយ ដើម្បីដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

អភិបាលខេត្ត ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានតាមការកំណត់ដូចខាងលើ ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុប រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ* សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច និងរដ្ឋសភា ព្រឹទ្ធសភាពិនិត្យអនុម័តអោយបានទាន់ពេលវេលា ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ធនាគារជាតិ
- សាលាខេត្ត ក្រុង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ក្រុង
- ធនាគារខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

លេខកូដ............

## តារាងបូកសរុបចំណូលថវិកាខេត្ត ក្រុង
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងឧបសម្ព័ន្ធ១

| ជំពូក | គណនី | អនុគណនី | បរិយាយ<br>ចំណាត់ថ្នាក់ចំណូល | ច្បាប់<br>ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្ត<br>ជាក់ស្តែង | សមាមាត្រ<br>ប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤=៣/២ | |
| | | | | | | | |
| | | | សរុបរួម | | | | |

| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលខេត្ត ក្រុង | ប្រធានរតនាគារខេត្ត ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង.........

លេខកូដ...........

## តារាងបូកសរុបចំណាយថវិកាខេត្ត ក្រុង

## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងឧបសម្ព័ន្ធ២

| ជំពូក | គណនី | អនុគណនី | បរិយាយ ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ឥណទានអនុញ្ញាត | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥=៤ / ៣ | |
| | | | | | | | | |
| | | | សរុបរួម | | | | | |

ហត្ថលេខា និងត្រា
អភិបាលខេត្ត ក្រុង

ហត្ថលេខា និងត្រា
ប្រធានរតនាគារខេត្ត ក្រុង

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា
អ្នកធ្វើតារាង